ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ........................

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងការពារជាតិមានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា តបតាមសំណើរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងការចូលសំចតនាវាយោធាកងទ័ពជើងទឹកប្រជាជនវៀតណាម ចំនួន០១គ្រឿង លេខ**២៦១** ដែលមាននាវិកសរុបចំនួន៣៧នាក់ ដឹកនាំដោយ វរនាវីឯកបំរ៉ុង **ម៉ាយ ដាំងហ្សាញ់** មេបញ្ជាការរង និងជានាយសេនាធិការ បញ្ជាការដ្ឋានតំបន់៥ កងទ័ពជើងទឹកប្រជាជនវៀតណាម បានចូលសំចតនៅកំពង់ផែមូលដ្ឋានសមុទ្ររាម ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៥។ ការចូលសំចតនាវារបស់កងទ័ពជើងទឹកប្រជាជនវៀតណាមនេះ ក្នុងគោលបំណងពង្រឹងចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការប្រកបដោយវិសាលភាពរវាងកងទ័ពជើងទឹកប្រទេសទាំងពីរ កម្ពុជា-វៀតណាម។

ការចូលសំចតនៅកំពង់ផែមូលដ្ឋានសមុទ្ររាមនេះ ជាការចូលសំចតនាវាបរទេសទី២ ដែលត្រូវបានអនុញ្ញាតឱ្យចូលសំចតនៅមូលដ្ឋានសមុទ្ររាម ក្រោយពីបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវមជ្ឈមណ្ឌលកស្ដុការ និងហ្វឹកហ្វឺនរួមគ្នា កម្ពុជា-ចិន ផែរាម កាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ ក្នុងអំឡុងពេលចូលសំចត គណៈប្រតិភូនាវានឹងអញ្ជើញចូលរួមកិច្ចប្រជុំដកបទពិសោធន៍លើកទី៣៥ ស្តីពីការងារល្បាតរួមលើកទី៧៧-៧៨ រវាងមូលដ្ឋានសមុទ្ររាម កងទ័ពជើងទឹក នៃកងយោធពលខេមរភូមិន្ទ ជាមួយបញ្ជាការដ្ឋានតំបន់៥ កងទ័ពជើងទឹកប្រជាជនវៀតណាម។ ជាមួយគ្នានេះ គណៈប្រតិភូក៏មានជំនួបពិភាក្សាការងារជាមួយ មេបញ្ជាការមូលដ្ឋានសមុទ្ររាម ក្នុងន័យលើកកម្ពស់ភាពស្និទ្ធស្នាល។

ដំណើរទស្សនកិច្ចខាងលើនេះ ជាព្រឹត្តិការណ៍សំខាន់មួយទៀត នៃទំនាក់ទំនងជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ឱ្យកាន់តែរឹងមាំស៊ីជម្រៅថែមទៀត។

ថ្ងៃ អង្គារ ៣កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៥